# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៧៧.១៧/០៤ **គ.ជ.ប**

## សេចក្ដីណែនាំរំលឹក

## ស្ដីពី

## ការពិនិត្យទទួល និងការដោះស្រាយបណ្ដឹងនៅ គឃ/សប ក្នុងដំណាក់កាលឃោសនាបោះឆ្នោត

អនុលោមតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ ព្រមទាំងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ក្នុងគោលដៅឱ្យការទទួល និងការដោះស្រាយបណ្ដឹង នៅ គឃ/សប ក្នុងដំណាក់កាលឃោសនាបោះឆ្នោត ប្រព្រឹត្តទៅដោយមានតម្លាភាព និងយុត្តិធម៌ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមណែនាំដល់គ្រប់ គខ/កប និង គឃ/សប ដូចខាងក្រោម ៖

**ក. ការពិនិត្យ និងទទួលពាក្យបណ្ដឹង**

១. នៅពេលអ្នកប្ដឹងមកដាក់ពាក្យបណ្ដឹង គឃ/សប ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនដូចជា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង កម្មវត្ថុនៃបណ្ដឹង និងពិនិត្យលើអំឡុងពេលដូចមានកំណត់ក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

២. ក្នុងករណី កម្មវត្ថុបណ្ដឹងមិនពាក់ព័ន្ធនឹងកិច្ចការឃោសនាបោះឆ្នោត ឬ/និងមិនគោរពអំឡុងពេលកំណត់ និងករណីបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ គឃ/សប ត្រូវចារបដិសេធលើពាក្យបណ្ដឹង ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបាន ហើយចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ។

៣. ក្នុងករណី មិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាងមិនមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ គឃ/សប ត្រូវណែនាំឱ្យបំពេញបន្ថែមចំណុចខ្វះខាត ដោយកត់ត្រានៅក្នុងកំណត់ហេតុ ។ ក្នុងករណី អ្នកប្ដឹងផ្ដល់ព័ត៌មានបន្ថែមមិនគ្រប់គ្រាន់តាមការណែនាំ និងទាន់ពេលវេលាកំណត់ គឃ/សប ត្រូវចារបដិសេធលើពាក្យបណ្ដឹង ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបាន ហើយចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ ។

៤. ក្នុងករណីអ្នកប្ដឹង ឬតំណាងយល់ឃើញថា ការចារបដិសេធរបស់ គឃ/សប មានលក្ខណៈមិនត្រឹមត្រូវ អ្នកប្ដឹង ឬតំណាងអាចដាក់ពាក្យបណ្ដឹងទៅ គខ/កប អំពីការចារបដិសេធរបស់ គឃ/សប រយៈពេលបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃ គឃ/សប ចារបដិសេធ ។

៥. ក្នុងករណី គឃ/សប ពិនិត្យឃើញថា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាងច្បាស់លាស់ កម្មវត្ថុនៃបណ្ដឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត និងគោរពអំឡុងពេលកំណត់ គឃ/សប ត្រូវទទួលពាក្យបណ្ដឹង ហើយធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាងភ្លាម ដោយត្រូវកត់ត្រាលើកំណត់ហេតុឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុនោះ ហើយចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ ។ ប្រសិនបើ គឃ/សប